ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
Ministry of Culture and Fine Arts



Reçu CLT/LHE
Le 31 MARS 2023
N° 0196









# បញ្ជីសារពើភណ្ឌ
# មរតកវប្បធម៌អរូបីកម្ពុជា
# Inventory of Intangible Cultural Heritage of Cambodia

២០១៩

2019

0211500007

**Krama or Kansaeng, a Cambodian Traditional Woven Textile with Grid Pattern Motifs**

"Krama" or "Kansaeng" is a Cambodian traditional woven textile – using cotton or synthetic or silk threads – with grid pattern motifs. The Krama term is borrowed from Persian language and it is perhaps introduced into Cambodia after 14th century CE. Krama term is popular among people, who live in cities or downtown. The Kansaeng term, however, is known by countryside people; While in other rural area, villagers sometimes employ the terms "Chhnuot" (turban) or "Sampot Dandop" (covering cloth).

In Khmer society, Krama is very useful and used in multiple functions associated with daily lives of people from birth to death, such as wrapping or covering a new born baby, a cover, for wearing at home or working in the field, as a turban, for covering the head, Peanea (to wrap a scarf diagonally across one's chest from the left shoulder to the right side), for drying sweat or water (from swimming or showering), wound bandage, for fanning, for whipping the fly or mosquito, Chorng Pong (wear as the skirt wrapped around the bosom), Peat Bat (apron or sleeveless upper garment), for wearing when bathing, for tying into a rope, a wrapping as a container or pocket, etc. Besides, Krama is used in association with offerings or as ritual objects, including covering areca flower in the wedding ceremony, wrapping around Dhung Rong (metal container with areca nut and betel leaf using as ritual object in the wedding ceremony), wrapping the Bay Praleung (sticky rice put in a green coconut shell and used in some specific rituals or ceremonies), wrapping around Bay Sei Dem (kind of ritual object made from banana trunk and leaves), spirit offering or offering for Preah Pishnukar god in other rituals or ceremonies or covering the ash in the Pre Rupe ritual and making hammock for lulling cremains in the funeral ceremony. In the traditional games, Krama is employed as game tools for the Chol Chhuong and Leak Kansaeng games, for blindfolding in Reav Bangkong and Veay Ka-om games during the Khmer New Year. Krama or Kansaeng is the theme for dance choreography or song lyrics. For people who have silk production tradition, they weave silk Karma and use it as valuable gift for their lovers, couples or daughter/son-in-laws. Some people believe that the using of silk Krama will brings good fortune and ward off the bad luck.

The knowhow of Krama weaving is continuously transmitted from one to the other generations till today and it is widespread in many places in the Kingdom of Cambodia, although its technique and production materials are developed or changed according to period and times. Recently, as observed, there are two kinds of Krama weaving loom: the traditional hand loom and the half-auto machine loom. The resource materials for textile weaving are cotton thread, synthetic yarn and silk thread. In the olden times, people use the threads made from natural cotton. Later on, they use the imported thread (perhaps from China) called "Hor thread". Krama that's made from the natural cotton thread or the Hor thread are convenient to use because it is soft and absorbs water quickly. Making Krama from the Hor thread has several processes, such as soaking the thread in water, wringing to make it dry, dyeing it, soaking and kneading the thread with the rice powder liquid, steaming it, drying the thread, and preparing the thread on the loom for weaving. The synthetic yarn called "Hong thread" is produced from factory and already has colors. It can be woven into Krama without undertaking any processes. However, the Krama made from this kind of thread does not absorb the water quickly and becomes shrunken after short use and is cheaper than the cotton yarn Krama. Another kind of Krama is made from silk, which is the local or imported products. Before weaving, the silk is dyed with natural or chemical colors. This process includes other difficult and long processes, such as planting mulberry, raising silk worms, untangling silk yarn from the silk worm. Silk scarf is magnificent and has a very high price. It is mostly made by villagers, who has the tradition associated with silk production and weaving

inherited from their ancestors. The natural colors used for silk dyeing are indigo, diospyros mollis (or Maklioe in Khmer), lacquer (from a kind of insect), garcinia vilersiana (or Prahuot in Khmer), and other colors extracted from other trees.

The community, who has maintained the tradition of producing natural dye from the indigo plant and has been famous for beautiful and high quality Krama production is the people living at Angkor Ban district, Kampong Cham province. Nowadays, Krama has a diverse color grid pattern motifs because people conduct experiments to test other trees or natural substances to get more colors to use and use also chemical colors.

Recently, based on the statistic surveyed there are more than one thousand textile weaving handicraft communities and families countywide. The representative textile weaving communities, who have actively participated in the preparation of this inventory are the Communities of Poay Char District in Banteay Mean Chey province, Angkor Ban and Krakor in Kampong Cham province, Prek Achi in Tbong Khmum province, Prek Changkran and Lve in Prei Veng province, Koh Andet and Kdanh in Takeo province, Koh Dach and Koh Oknha Tei in Phnom Penh. Besides, there are also relevant associations, including Khmer Golden Silk, Golden Silk Pheach, Taan Weaves, Institute of Khmer Traditional Textiles (IKTT), and Color Silk.

BIBLIOGRAPHIES

Kem, Sonin, 2005-2006, "The Looms of Kean Svay Villagers", *Khmer Renaissance*, No. 1, Phnom Penh, pp. 20-22. (Khmer Language)

Chea Narin, Chea Sopheary, Kem Sonin, and Preap Chan Mara, 2003, *The Seam of Change: Clothing and the Care of the Self in Late 19th and 20th Century Cambodia,* Reyum, Phnom Penh. (English and Khmer Language)

Chea, Pisey, 1994, *Khmer Krama Weaving*, B.A. Thesis, Faculty of Archaeology, Royal University of Fine Arts, Phnom Penh. (Khmer Language)

Pou, Savaros, 1992, *Old Khmer-French-English Dictionary*, Paris.

Uch Kang Keriya Pheakdei, Heng Chhun Oeun, and Hor Ritheanuo, 2000, *The Display of Ancient Khmer Traditional Crafts*, B.A. Thesis, Faculty of Archaeology, Royal University of Fine Arts, Phnom Penh. (Khmer Language)

Paul, Levy, 1941, *Recherche préhistorique dans la région de Mlu Prie*, Indication de L' école Français d' Extrème – Orient.

Norodom, Sihanouk, (Undated), *Photo-Souvenirs de mon Cambodge (ANNEES 60).*

# ១. ក្រមា ឬ កន្សែង

*Krama or Kansaeng (a Cambodian Traditional Woven Textile with Grid Pattern motifs)*

| | |
|---|---|
| សហគមន៍ ឬ ទីតាំងប្រតិបត្តិ | ទូទាំងប្រទេស |
| ប្រភេទ | សិប្បកម្មប្រពៃណី |
| ពេលវេលា | មិនកំណត់ពេល |



អ្នកស្រុកជួតក្បាលក្រមា

## ពិពណ៌នា

"ក្រមា" ឬ "កន្សែង" គឺជាសំពត់ត្បាញដោយអំបោះ ឬសូត្រ មានក្រឡាខ្វែងៗ ក្រមា គឺជាពាក្យដែលខ្មែរខ្ចីពីភាសារបស់ពែរ្ស (Persian) ដែលប្រហែលជាចូលមកខ្មែរក្រោយសតវត្សទី១២។ ភាគច្រើនជាអ្នកនៅទីក្រុង ឬទីប្រជុំជនដែលនិយមប្រើពាក្យក្រមា រីឯអ្នកជនបទនិយមប្រើពាក្យកន្សែងជាង។ ជួនកាលទៀតអ្នកស្រុកហៅថា "ឈ្នួត" ឬ "សំពត់ដណ្តប់" ផងក៏មាន គឺអាស្រ័យទៅតាមតំបន់។

ក្នុងសង្គមខ្មែរ ក្រមាមានប្រយោជន៍ច្រើនណាស់សម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃខ្វះពុំបាន តាំងពីកើតរហូតដល់ស្លាប់ ដូចជាយកទៅរុំ ឬដណ្តប់ឱ្យទារកទើបកើត, ចងធ្វើអង្រឹងឱ្យទារកដេក, ធ្វើជាកម្រាលផ្សេងៗ, ស្លៀកនៅផ្ទះ ឬធ្វើកិច្ចការផ្សេងៗ, ជួតក្បាល, ទទូរ, ពានា, ជូតញើស ឬជូតខ្លួន, ចង ឬរុំរបួស, បក់ឱ្យរហើយ, បក់រុយ ឬមូស, ចោមពុង, ពាតបា (អាវអៀម), ផ្ទាស់ងូតទឹក, ធ្វើជាចំណង ឬចងប្រទាក់គ្នាធ្វើពួរ, ចងធ្វើថ្នក់ដាក់របស់របរផ្សេងៗតាមសេចក្តីត្រូវការ។ល។ ក្រៅពីប្រើប្រាស់ ក្រមាឃើញមានប្រើជាផ្នែកខ្លះនៃរណ្តាប់ ឬប្រើជារណ្តាប់ដូចជា រុំផ្កាស្លាក្នុងពិធីមង្គលការ, រុំថង់រង, រុំបាយព្រលឹង, រុំបាយស្រីដើម, ធ្វើជាទ្រនាប់គ្រូ ឬរណ្តាប់ព្រះពិស្ណុការក្នុងកិច្ចពិធីផ្សេងៗ ឬប្រើក្នុងកិច្ចប្រែរូប និងបំពេរធាតុក្នុងពិធីបុណ្យសពជាដើម។ រីឯក្នុងល្បែងប្រជាប្រិយ គេយកក្រមាចងធ្វើឈូង ឬលេងលាក់កន្សែង, ចងមុខលេងរាវបង្គង ឬលេងវាយក្អមពេលចូលឆ្នាំជាដើម។ ក្រមា ឬកន្សែង ត្រូវគេយកទៅដំឡើងជារបាំរាំលើឆាក និងចងក្រងជាទំនុកច្រៀង។ ចំពោះអ្នកស្រុកដែលមានប្រពៃណីថ្កុំថ្កើងជាប់ជាមួយសូត្រ គេយកក្រមាសូត្រជារបស់ប្រចាំចិត្ត ឬចំណងដៃគូសង្សារ គូករិយាស្វាមី ឬកូនប្រុសា។



អ្នកស្រុកបង៉កក្រមាក្នុងចម្លាក់ប្រាសាទបាយ័ន្ត





ក្រមាប្រើជាគ្រឿងរណ្តាប់ (រូបឆ្វេង), ក្រមាប្រើក្នុងកិច្ចប្រែរូបនៃពិធីបុណ្យសព (រូបស្តាំ)



ពានក្រមា



ស្នៀកក្រមាប្រកួតប្រដាល់ប្រពៃណី
(រូបថតៈ ព្រះតេជគុណ ភា ឡេហ៊ាង)



ចងថ្នក់ក្រមាស្ពាយកូន

ខ្លះជឿថា ការប្រើប្រាស់ក្រមាសូត្រជួយលើករាសី និងអាចការពារខ្លួនពីការបៀតបៀននានាផង។

ចំណេះជំនាញត្បាញក្រមា បានផ្ទេរបន្តឥតដាច់ពីជំនាន់មួយទៅជំនាន់មួយរហូតមកដល់សព្វថ្ងៃ ហើយរីកដុះដាលនៅតាមស្រុក តាមតំបន់ជាច្រើនទូទាំងព្រះរាជាណាចក្រកម្ពុជា បើទោះបីជាបច្ចេកទេស និងសម្ភារៈផលិតមានការវិវឌ្ឍខ្លះៗទៅតាមសម័យកាល និងពេលវេលាក៏ដោយ។ តាមការសង្កេត បច្ចុប្បន្នកីត្បាញក្រមាមានពីរប្រភេទ គឺកីត្បាញដោយដៃ និងកីពាក់កណ្តាលស្វ័យប្រវត្តិ ពោលគឺការត្បាញដោយប្រើម៉ាស៊ីនជាជំនួយ។ ចំណែកវត្ថុធាតុសំខាន់ដែលយកមកត្បាញក្រមា គឺអំបោះសម្ទី ឬអំបោះហោ ឬអំបោះទៅ, អំបោះហុង និងអំបោះសូត្រ។ ពីបុរាណមក អ្នកស្រុកប្រើអំបោះដែលផលិតចេញពីសម្ទីកប្បាស ឬសម្ទីគ។ ក្រោយមកមានប្រភេទអំបោះដែលនាំចូលពីក្រៅប្រទេស (ប្រហែលមកពីចិន) ដែលអ្នកស្រុកហៅថា "អំបោះហោ"។ អំបោះសម្ទី និងអំបោះហោ ជាប្រភេទអំបោះទៅ ដែលត្បាញជាក្រមា គឺជក់ទឹកល្អ និងទន់ងាយស្រួលប្រើប្រាស់




គីតម្បាញប្រពៃណី (រូបឆ្វេង), គីពាក់កណ្តាលស្វ័យប្រវត្តិ (រូបស្តាំ)




កប្បាសសម្រាប់ធ្វើសរសៃអំបោះ (រូបឆ្វេង, រូបថតៈព្រឹត្តិបត្រ MON CAMBODGE), អំបោះហោ ឬអំបោះឆៅ (រូបស្តាំ)

ណាស់។ ការផលិតក្រមាពីអំបោះហោមានច្រើនដំណាក់កាល ពោលគឺគេយកអំបោះឆៅនោះទៅត្រាំទឹក(១-២យប់)រួចពូតឲ្យស្ងួត, ជ្រលក់ពណ៌, ឲ្យបាយ, ចំហុយ, ហាលថ្ងៃ ទើបយកទៅអន្ទងនឹងកីដើម្បីត្បាញ។ ចំណែក "អំបោះហុង" គឺជាប្រភេទអំបោះដែលផលិតចេញពីរោងចក្រមានពណ៌ស្រាប់។ គេយកមកអន្ទងនឹងកីហើយត្បាញជាក្រមាតែម្តង ដោយពុំចាំបាច់ឆ្លងកាត់ដំណាក់កាលច្រើនដូចអំបោះហោនោះទេ។ ក្រមាធ្វើពីអំបោះហុង មិនសូវជក់ទឹកល្អ និងឆាប់រួញ ហើយក៏មានតម្លៃថោកជាងក្រមាអំបោះឆៅឬអំបោះហោ។ក្រមាមួយប្រភេទទៀតគឺផលិតចេញពីសរសៃសូត្រ ដែលសូត្រនោះផលិតក្នុងស្រុក ឬនាំចូលពីក្រៅប្រទេស។ សូត្រត្រូវជ្រលក់ពណ៌ (មានទាំងពណ៌ធម្មជាតិ និងពណ៌គីមី) មុននឹងយកទៅអន្ទងត្បាញ។ នេះពុំរាប់ពីដំណាក់កាលដ៏លំបាកនិងប្រើពេលយូរក្នុងការដាំមន, ចិញ្ចឹមដង្កូវនាង (ឬកូននាង) និងស្រាវយកសូត្រនោះផងទេ។ ក្រមាសូត្រមានភាពប្រណីត និងមានតម្លៃខ្ពស់ ហើយច្រើនតែត្បាញដោយអ្នកស្រុក ដែលមានប្រពៃណីជាប់ជាមួយការផលិតសូត្រ និងតម្បាញសំពត់សូត្រតាំងពីដូនតាមក។ ពណ៌ធម្មជាតិប្រើសម្រាប់ជ្រលក់សូត្រឬអំបោះ មានត្រុំ, ផ្លែមក្លឿ, ល័ក្ត, សំបកព្រហូត និងពណ៌ពីដើមឈើផ្សេងទៀត។



ក្រមាសូត្រ





ដើមត្រុំ (រូបលើ), ល្បាប់មរត្រុំ (រូបកណ្តាល), ក្រមាជ្រលក់ពណ៌ត្រុំ (រូបក្រោម)



ក្រមាដែលមានពណ៌ចម្រុះ



សហគមន៍ដែលនៅរក្សាប្រពៃណីផលិតពណ៌ត្រុំ និងមានក្រមាល្បីល្បាញនោះគឺអ្នកស្រុកអង្គរបានក្នុងខេត្តកំពង់ចាម។ សព្វថ្ងៃ ក្រមាមានពណ៌ច្រើនដោយសារការពិសោធជ្រលក់ពណ៌ពីធម្មជាតិផ្សេងៗ និងការប្រើពណ៌គីមីដែលមានច្រើនពណ៌ ។

សព្វថ្ងៃ យើងសង្កេតឃើញមានសិប្បកម្មតម្បាញជាងមួយពាន់កន្លែងនៅទូទាំងប្រទេស។ ក្នុងនោះតម្បាញក្រមាដែលផុលផុស ហើយបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំបញ្ជីសារពើភណ្ឌនេះរួមមាន សហគមន៍នៅឃុំប៉ោយចារ ខេត្តបន្ទាយមានជ័យ, អង្គរបាននិងក្រគរ ខេត្តកំពង់ចាម, ព្រៃកអាជី ខេត្តត្បូងឃ្មុំ, ព្រែកចង្ក្រាននិងល្វេ ខេត្តព្រៃវែង, កោះអណ្តែតនិងក្តាញ់ ខេត្តតាកែវ, កោះដាច់និងកោះឧកញ៉ាតី រាជធានីភ្នំពេញ។ ក្រៅពីនោះក៏មានសមាគមដែរ ដូចជាសូត្រមាសខ្មែរ, សូត្រកាជមាស, សហគមតាអាន, វិទ្យាស្ថានវាយនភ័ណ្ឌប្រពៃណីខ្មែរ និងសូត្រពណ៌។

## ឯកសារពិគ្រោះ


កែម សុនីន, ២០០៥-២០០៦, "កីតម្បាញក្រមារបស់អ្នកកៀនស្វាយ", **ការម្រង អត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ**, លេខ១. ភ្នំពេញ, ទំ.២០-២២។

ជា ណារិន, ជា សោភារី, កែម សុនីន, ព្រាប ចាន់ម៉ារ៉ា, ២០០៣, **ស្លៀកពាក់ និងថែរក្សាខ្លួនចុងសតវត្សទី១៩ ដល់សតវត្សទី២០**, រីឃំ, ភ្នំពេញ។

ជា ពិសី, ១៩៩៤, **តម្បាញក្រមាខ្មែរ**, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

ពៅ សាវរស, ១៩៩២, **វចនានុក្រមខ្មែរចាស់-បារាំង-អង់គ្លេស**, ប៉ារីស៍។

អ៊ុច កង់កិរិយាភក្តី, ហេង ឈុនអៀន, ហ៊ិរ វិទ្ធានូ, ២០០០, **ការបង្ហាញប្រភេទសិប្បកម្មខ្មែរសម័យបុរាណ**, និក្ខេបបទបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

Paul, Levy,1941, *Recherche préhistoriques dans la région de Mlu Prei,* l' école Française d' Etrême-Orient.

Norodom, Sihanouk, (Undated), *Photos-Souvenirs de mon Cambodge (ANNEES 60).*